# លក្ខណៈសំណង់ប្រាសាទអូរស្វាយ និង សិលាចារឹកកំណត់ព្រំដែនសីមា

ដោយ : **បណ្ឌិត ផុន កសិកា**

ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

រាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ប្រាសាទអូរស្វាយ ស្ថិតក្នុងឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដែលមានចំងាយប្រមាណ១៩គីឡូម៉ែត្រ ពីទីរួមស្រុកត្រពាំងប្រាសាទ។ ទីតាំងប្រាសាទស្ថិតនៅជិតជើងភ្នំដងរែក មិនដល់១គីឡូម៉ែត្រផង។

កាលពីឆ្នាំ២០១០ ក្រុមស្រាវជ្រាវដែលដឹកនាំលោក ផុន កសិកា[1] បានចុះសិក្សាស្រាវជ្រាវនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្នុងគោលបំណងសិក្សាស្រាវជ្រាវស្វែងរកប្រាសាទ ស្ថានីយបុរាណនានា ដើម្បីចងក្រងទុកជាឯកសារស្រាវជ្រាវ ចុះបញ្ជីស្ថានីយទាំងនោះក្នុងបញ្ជីបេតិកភណ្ឌ ដែលជាទិន្នន័យសំខាន់សម្រាប់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈអាចយកទៅប្រើប្រាស់សម្រាប់កំណត់ដែនការពារស្ថានីយបុរាណ។



ផែនទីស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

[1] នៅឆ្នាំ២០១០ លោក ផុន កសិកា បម្រើការនៅវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា ហើយនៅឆ្នាំ២០១៩ ទទួលតួនាទីជាប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា។

លទ្ធផលស្រាវជ្រាវនៅឆ្នាំ២០១០ បានរកឃើញប្រាសាទ និងទួលប្រាសាទ ឬគ្រឹះប្រាសាទចំនួន២៩ ស្ថានីយយកថ្មបាយក្រៀមចំនួន២កន្លែង ស្ថានីយយកថ្មភក់ និងសិប្បកម្មថ្មភក់១កន្លែង ថ្មគោលចំនួន៣ ព្រមទាំងភូមិបុរាណ ត្រពាំងបុរាណ និងទំនប់បុរាណមួយចំនួនទៀត[2]។

នៅខែវិច្ឆិកា ឆ្នាំ២០២៤ ប្រជាពលរដ្ឋម្នាក់បានប្រគល់សិលាចារឹកមួយផ្ទាំងជូនដល់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ដើម្បីថែរក្សា និង សម្រាប់សិក្សាស្រាវជ្រាវ។ ឯកឧត្តមបណ្ឌិត មាឃ បូរ៉ា គឺជាប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា បានចាប់អារម្មណ៍ចំពោះសិលាចារឹក និងបានសិក្សានិងប្រែសិលាចារឹកនេះ។

អត្ថបទនេះនឹងបកស្រាយអំពីលក្ខណៈនៃរចនាសម្ព័ន្ធសំណង់ប្រាសាទអូរស្វាយ និងអត្ថន័យនៃសិលាចារឹកដែលទើបរកឃើញ។

ការសិក្សាស្រាវជ្រាវពឹងផ្អែកលើការសិក្សាចុះដល់ទីតាំងប្រាសាទ ថតរូប ប្រើឧបករណ៍ដ្រូនដើម្បីជួយដល់ការផ្ដិតយករូបភាពពីលើអាកាស ប្រើរូបភាព Google Earth សម្រាប់សិក្សាបន្ថែមអំពីភូមិសាស្ត្រនិងសិក្សាទំហំប្រាសាទ និងទំហំបារាយណ៍។ ការសិក្សាបានសម្ភាសប្រជាពលរដ្ឋដែលបានប្រគល់សិលាចារឹកដល់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ។



ផែនទីប្រាសាទអូរស្វាយ ក្នុងឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ (ផលិត : លោក ឡេង សត្យា)

[2] ផុន កសិកា «ប្រាសាទរកឃើញថ្មីៗ និងការធ្វើផែនទីស្ថានីយបុរាណ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ» រាជបណ្ឌិត្យសភាកម្ពុជា, ២០១២។




ផែនទីបង្ហាញពីទីតាំងប្រាសាទអូរស្វាយ

(ប្រភព : ផុន កសិកា ២០១២)

## ១. រចនាសម្ព័ន្ធសំណង់ប្រាសាទអូរស្វាយ

ប្រាសាទអូរស្វាយសង់ពីថ្មបាយក្រៀមសម្រាប់កំពែងប្រាសាទនិងខ្លោងទ្វារ។ ក្រៅពីនោះក៏មានថ្មភក់សម្រាប់គ្រឿងបង្គំប្រាសាទ និង គ្រឿងលម្អផ្សេងៗដូចជា មេទ្វារ ផ្តែរ ហោរជាង សសរពេជ្រ នាងប្រាលដែលសង់ដាក់នៅលើកំពែងប្រាសាទ។



នាងប្រាល ផ្តែរ និងបំណែកថ្មភក់ផ្សេងៗដែលដាក់ក្នុងខ្ទមអ្នកតា (រូបថតឆ្នាំ២០១០)



នាងប្រាលនិងវត្ថុបុរាណផ្សេងទៀតក្នុងខ្ទមអ្នកតា (ថតឆ្នាំ២០២៥)



ថ្មភក់ស្ថិតនៅលើកំពែងគឺជាទ្រនប់ដាក់នាងប្រាល



នាងប្រាលប្រាសាទប្រាង្គ កោះកេរ

(រូបថត : លោក ថូ ថុន)



នាងប្រាលប្រាសាទប្រាង្គ កោះកេរ

(រូបថត : លោក ថូ ថុន)

មួយវិញទៀតសំណង់ប្រាសាទអូរស្វាយ ក៏មានពីឥដ្ឋដែរ ជាឥដ្ឋដែលគេយកមកសង់សម្រាប់តួប្រាសាទ។ តួប្រាសាទអូរស្វាយ មានតួកណ្ដាល១សង់ពីឥដ្ឋ ប៉ុន្តែបច្ចុប្បន្នបាក់បែករលំដល់ដី។



តួកណ្ដាលសង់ពីឥដ្ឋ (ថតពីទិសខាងកើត)



តួកណ្ដាលសង់ពីឥដ្ឋ (ថតពីទិសខាងត្បូង)

សំណង់ប្រាសាទអូរស្វាយ ក្រៅពីកំពែងក្រៅពីតួប្រាសាទមានសំណង់មួយទៀតគឺហោរត្រៃ។ ហោរត្រៃសង់ពីថ្មបាយក្រៀម បែរមុខទៅទិសខាងលិច។



ហោត្រ៍យ



របនាសម្ព័ន្ធសំណង់ប្រាសាទអូរស្វាយមើលពីលើ

ចំពោះទំហំកំពែងប្រាសាទមានបណ្ដោយប្រវែង៣០ម៉ែត្រ និង ទទឹងប្រវែង២៥ម៉ែត្រ។



កំពែងប្រាសាទមើលពីទិសនិរតី

ប្រាសាទអូរស្វាយបែរមុខទៅទិសខាងកើត មានគូទឹកស្ទើរជុំវិញ ប៉ុន្តែគូទឹកមិនព័ទ្ធជុំវិញទាំងអស់ទេ ទុកច្រកនៅជ្រុងខាងកើត ដោយសារ ជ្រុងខាងកើតត្រូវឱ្យមានផ្លូវចេញចូលមកប្រាសាទ។ រីឯ ជ្រុងខាងជើង លិច ខាងត្បូងមានគូទឹក។



ខ្លោងទ្វារខាងកើត



ខ្លោងទ្វារខាងលិច



គូទឹកជ្រុងពាយព្យ

បារាយណ៍ដែលសាងនៅខាងកើតប្រាសាទ ចម្ងាយប្រមាណ១៨០ ម៉ែត្រពីប្រាសាទ ដែលជាលក្ខណៈនៃរចនាសម្ព័ន្ធសំណង់ប្រាសាទនៅសម័យអង្គរ (ប្រាសាទ និង បារាយណ៍នៅទិសខាងកើត)។ បារាយណ៍មានបណ្ដោយប្រវែង៣៨៥ម៉ែត្រនិងទទឹង២០០ម៉ែត្រ។

អក្សរកើតលិចប្រវែង៣៨៥ម៉ែត្រ រីឯអក្សរជើងត្បូងប្រវែង២០០ម៉ែត្រ។



បារាយណ៍ស្ថិតនៅខាងកើតប្រាសាទ




ប្រាសាទនិងបារាយណ៍នៃប្រាសាទអូរស្វាយ

(ប្រភព : Google Earth)

## ផ្តែរ

នៅក្នុងប្រាសាទអូរស្វាយមានផ្តែរដែលជាគ្រឿងសំណង់ ឬ ជាគ្រឿងបង្គុំប្រាសាទមួយមានក្បាច់រចនាឆ្លាក់តាមរចនាបថច្បាស់លាស់ និងរក្សាស្ថានភាពល្អ។ តាមរយៈផ្តែរនេះ យើងអាចសន្និដ្ឋានអំពីរចនាបថនិងអាយុកាលរបស់ប្រាសាទបាន។ ផ្តែរមាននៅក្នុងបរិវេណប្រាសាទអូរស្វាយមានចំនួន៤៖

**ផ្តែរទី១** : អ្នកស្រុកយកទៅរក្សាទុកនៅក្នុងខ្ទមមួយ ជាលក្ខណៈខ្ទមគោរពបូជា (រោងអ្នកតា)។ នៅក្នុងរោងអ្នកតានោះ គេក៏ប្រមូលវត្ថុសិល្បៈមួយចំនួនមកតម្រៀបជាមួយផ្តែរដែរ។ ទីតាំងរោងអ្នកតាស្ថិតក្នុងបរិវេណប្រាសាទ នៅខាងលិចជិតតួប្រាសាទកណ្តាល។ ការណ៍ដែលយកវត្ថុបុរាណមកផ្តុំគ្នាបែបនេះ ក្នុងគោលបំណងយកកន្លែងនេះជាទីគោរពបូជា។ ផ្តែរទី១មានក្បាច់កណ្តាលផ្តែររចនាជារូបរាហ៊ូហាមាត់ ដៃកាន់កម្រងផ្កាដែលជាអក្សរដងធ្នូរ និងក្បាច់ផ្កាសន្ទឹកនៅពីលើ និង ក្រោមដងធ្នូរ។ នៅពីលើចម្លាក់រាហ៊ូមានចម្លាក់រូបមនុស្សគឺជាព្រះកាល។



ផ្តែរទី១ស្ថិតក្នុងខ្ទមអ្នកតា

**ផ្តែរទី២** : ស្ថិតនៅមុខសំណង់ហោត្រៃ។ ផ្តែរនេះក៏មានក្បាច់ចម្លាក់ស្ទើរដូចគ្នានឹងផ្តែរទី១ដែរ មាន រាហ៊ូហាមាត់ ដៃកាន់កម្រងផ្កា មានព្រះកាលនៅចំកណ្តាលដូចគ្នានឹងផ្តែរទី១ដែរ។



ផ្តែរទី២ស្ថិតនៅមុខហោត្រៃ

**ផ្តែរទី៣** : ផ្តែរទី៣ គេដាក់នៅជាប់តួកណ្តាលដែលជាសង់ពីឥដ្ឋ ជាផ្តែរដែលមានសភាពសឹករិចរឹលខ្លាំង។ ផ្តែរនេះជាប្រភេទផ្តែរនព្វគ្រោះ ឬ ផ្តែរផ្កាយនព្វគ្រោះ មានដូចជា ព្រះអាទិត្យ ព្រះច័ន្ទ ព្រះវាយោ ព្រះយម ព្រះឥន្ទ្រ ព្រះវរុណ ព្រះអគ្និ ព្រះរាហ៊ូ និង ព្រះកេតុ[3]។



ផ្តែរទី៣ជាប្រភេទផ្តែរនព្វគ្រោះ



Figure 5. *Navadevas* panel from Kuk Roka temple, ca. late 12th century. Stone. National Museum of Cambodia, Phnom Penh, Ka.1658. Deities from left: Sūrya, Candra, Yama (?), Brahmā or Varuṇa, Indra, Kubera, Agni, Rāhu and Ketu. Photograph by Chhum Menghong (CC BY-NC 4.0).

ផ្តែរផ្កាយនព្វគ្រោះនៅសារៈមន្ទីរជាតិភ្នំពេញ

(ប្រភព : Chhum Menghong)

**ផ្តែរទី៤** : ស្ថិតនៅខាងក្រៅជាប់កំពែងជ្រុងនិរតី។ ផ្តែរនេះក៏មានក្បាច់លម្អដូចនឹងផ្តែរទី១ដែរ ទោះបីជា យើងអាចមើលឃើញតែមួយបំណែក ដោយសារបាំងនឹងគំនរថ្មបាយក្រៀមដែលរលំបាំងផ្តែរនោះ។



ផ្តែរស្ថិតកប់ក្នុងគំនរថ្មនៃកំពែងខាងកើត

តាមរយៈរចនាសម្ព័ន្ធសំណង់ដែលមានសំណង់ថ្មបាយក្រៀម មានគូទឹកព័ទ្ធជុំវិញ និង មានបារាយណ៍ នៅខាងកើតបែបនេះគឺជាសំណង់មួយបានវិវត្តបច្ចេកខ្ពស់ ក្នុងសម័យអង្គរ។ ប៉ុន្តែនៅក្នុងសម័យអង្គរមានរយៈពេលយូរចាប់ពីសតវត្សរ៍ទី៩ ដល់១៥។ បើយើងពិចារណាលើក្បាច់ចម្លាក់ផ្តែរ និងតាមការសិក្សាស្រាវជ្រាវរបស់អ្នកស្រាវជ្រាវមុនៗ ផ្តែរដែលមានក្បាច់ដូចខាងលើ គេអាចចាត់ទុកថាជាផ្តែរឆ្លាក់នៅរចនាបថឃ្លាំង សតវត្សរ៍ទី១១

[3] *សូមអាន* Chhum, M. (2020). Nine Deities Panel in Ancient Cambodia [*ផ្ទាំងចម្លាក់ទេពប្រាំបួនអង្គក្នុងអារ្យធម៌ខ្មែរបុរាណ*]. Pratu: Journal of Buddhist and Hindu Art, Architecture and Archaeology of Ancient to Premodern Southeast Asia, 1(2), 1-17. https://doi.org/10.25501/SOAS.00032560

នៅក្នុងរាជព្រះបាទព្រះបាទសូរ្យវរ្ម័នទី១ (ឆ្នាំ ១០០៦-១០៥០)។ ប៉ុន្តែរយៈពេលណាមួយនោះច្បាស់លាស់ យើងមិនអាចដឹងច្បាស់លាស់ទេ។ ដូច្នេះហើយ មានតែសិលាចារឹកទេ ដែលអាចចាររៀបរាប់អំពីរឿងរ៉ាវផ្សេងៗទាក់ទងនឹងប្រាសាទ ឬ អាយុកាលនៃការសាងសង់ប្រាសាទ។



Fig. 37. — Linteaux décoratifs : a. Prè Rup ; b. Banteay Srei ; c. Palais Royal d'Angkor Thom.

ផ្តែររចនាបថឃ្លាំងយកពីរាជវាំងក្រុងអង្គរធំ

(ប្រភព : Boisselier: 153, 1966)

## ២.សិលាចារឹករកឃើញនៅប្រាសាទអូរស្វាយ

កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ មន្ត្រីជំនាញនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មានដូចជា លោក អ៊ីង ពៅ លោក និង លោក សឿង គាសា ដោយមានកិច្ចសហការជាមួយអាជ្ញាធរដែនដី និង នគរបាលការពារបេតិកណ្ឌផងនោះ បានទទួលសិលាចារឹកប្រាសាទអូរស្វាយ ដែលរកឃើញ (នៅជិតប្រាសាទអូរស្វាយ) ដោយលោក ថាច់ ជុំ រស់នៅភូមិឈូកស ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីយកទៅថែរក្សាទុកនៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ[4]។

ការពិត អ៊ិន អ៊ាន គឺជាអ្នកបានរកឃើញសិលាចារឹកនេះនៅវាលស្មៅចម្ងាយប្រមាណជា៣០០ម៉ែត្រពីប្រាសាទដែលជាកន្លែងគាត់ឃ្វាលគោ តាំងពីឆ្នាំ១៩៩៨។ បន្ទាប់មកគាត់ក៏យកមកទុកនៅផ្ទះរហូតដល់មន្ត្រីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈមកស្នើយកទៅថែរក្សានៅមន្ទីរ នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤។

លោកអ៊ិន អ៊ាន[5] គឺជាប្រជាពលរដ្ឋរស់នៅឃុំព្រះប្រឡាយ[6] តែបច្ចុប្បន្នបានដូរមកស្ថិតក្នុងឃុំអូរស្វាយវិញ។ មុនជំនាន់ផ្តាច់ខ្លួនគេហៅ ឃុំព្រះប្រឡាយ ដល់ពេលឥឡូវដាក់បញ្ចូលក្នុងឃុំអូរស្វាយវិញ។

[4] របាយការណ៍របស់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យចុះនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤។

[5] សម្ភាសលោក អ៊ិន អ៊ាន នៅបរិវេណប្រាសាទអូរស្វាយ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥។

[6] ប្រាសាទអូរស្វាយស្ថិតក្នុងឃុំព្រះប្រឡាយ ប៉ុន្តែ បច្ចុប្បន្នត្រូវបានប្តូរឈ្មោះឱ្យស្ថិតក្នុងឃុំអូរស្វាយវិញ បន្ទាប់ពីកងទ័ពខ្មែរក្រហមបានធ្វើសមាហរណកម្មផ្តាច់ខ្លួនពីកងកម្លាំងខ្មែរក្រហម។



លោក អ៊ិន អ៊ាន គឺជាអ្នករកឃើញសិលាចារឹក



មន្ត្រីជំនាញនៃមន្ទីរវប្បធម៌និងវិចិត្រខេត្តឧត្តរមានជ័យ ទទួលសិលាចារឹកពីអ្នកភូមិដែលរក្សាទុកជំនួស លោក អ៊ិន អ៊ាន់ (ប្រភព : លោក អ៊ីង ពៅ)



សិលាចារឹកប្រាសាទអូរស្វាយ ជ្រុងក



សិលាចារឹកប្រាសាទអូរស្វាយ ជ្រុងខ

**ខ្លឹមសារសិលាចារឹកប្រាសាទអូរស្វាយ**

សិលាចារឹកប្រាសាទអូរស្វាយបាក់ផ្នែកខាងលើ ដែលយើងមិនដឹងថាមានចំនួនអក្សរប៉ុន្មានបន្ទាត់។ សិលាចារឹកនេះត្រូវបានគេចារទាំងពីរជ្រុង។ ជ្រុង «ក» នៅសល់១៩បន្ទាត់ មួយជ្រុងទៀត ជ្រុង «ខ» សល់១៣បន្ទាត់។

ចំពោះស្ថានភាពសិលាចារឹក គេសរសេរលើគោលសីមា ដែលបន្ទះនៃគោលសីមាបាក់ផ្នែកខាងលើគឺមានន័យថា តួអក្សរមួយចំនួនបាត់។ អក្សរនៅសល់មួយចំនួន ហើយមួយចំនួនទៀតសឹករិចរឹល មិនអាចអានបាន។

សិលាចារឹកនេះគឺជាសិលាចារឹកថ្មីចារជាភាសាខ្មែរ និងមិនទាន់មានការសិក្សាស្រាវជ្រាវនៅឡើយ។ ទម្រង់តួអក្សរស្ទើរជា

អក្សរជ្រៀង និងមិនមែនអក្សរមូល មានខ្លះមូល ខ្លះជ្រៀង។

តាមការបកស្រាយរបស់ឯកឧត្តមបណ្ឌិត មាឃ បូរ៉ា ប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា បង្ហាញថា សិលាចារឹកអូរស្វាយ រៀបរាប់អំពីការកំណត់ព្រំដីមួយសម្រាប់ទីតាំងមួយនៅតំបន់ជុំវិញប្រាសាទអូរស្វាយ ដោយបង្ហាញអំពីទិសផ្សេងៗ។ សិលាចារឹករៀបរាប់អំពីព្រំប្រទល់ដី ឧទាហរណ៍ ទិសខាងលិចទល់ណា ទិសខាងត្បូងទល់ណា ទិសទស្សិណ ទិសបច្ចឹម និងទិសឧត្តរ។ សិលាចារឹកក៏បង្ហាញព្រះនាមព្រះកម្រតេងអញស្រីសង្គ ស្រីកសង្គៈ ដែលអាចជាព្រះនាមព្រះអង្គម្ចាស់ ឬក៏មន្ត្រីថ្នាក់ខ្ពស់[7]។

## ៣.ថ្មគោល

ការស្រាវជ្រាវនៅឆ្នាំ២០១០ បានរកឃើញថ្មគោលធ្វើពីថ្មភក់ មាននិយាមការ (X= ៤៣៣៩៣៣, Y= ១៥៨១៧៨៦) នៅក្នុងភូមិទួលគ្រួស ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ថ្មគោលនេះបណ្ដោយប្រវែង១៣០ ស.ម. និងទទឹងប្រវែង៤៦ ស.ម.[8]។



ថ្មគោលរកឃើញនៅភូមិទួលគ្រួស



ផែនទីថ្មគោលក្នុងភូមិទួលគ្រួស

[7] មាឃ បូរ៉ា «វីដេអូឯកសារស្ដីពី សិលាចារឹកបង្ហាញព្រំដីនៅប្រាសាទអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ» បង្ហោះតាមហ្វេសប៊ុកផេកវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា (https://www.facebook.com/share/v/19BEgkQous/) នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥។

[8] ផុន កសិកា «ប្រាសាទរកឃើញថ្មីៗ និងការធ្វើផែនទីស្ថានីយបុរាណ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ» រាជបណ្ឌិត្យសភាកម្ពុជា, ២០១២ ទំព័រ ៥៦។

ខ្ញុំលើកយកកស្តុតាងថ្មគោលមួយចំនួនទៀតដែលរកឃើញនៅស្ថានីយផ្សេងៗ ពិសេសក្នុងខេត្តឧត្តរមានជ័យ៖

ថ្មគោលមានចំណុចនិយាមការ (X= ៤៣៧៩០៦, Y= ១៥៤៥៨៦៣) រកឃើញនៅក្នុងភូមិពានមាស ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ថ្មគោលនេះមានរាងជ្រុងមានបណ្តោយប្រវែងមិនលើសពី ១៣០ស.ម ទទឹង៥០ស.ម. និងកម្រាស់៣០ស.ម.។ នៅផ្នែកខាងលើនៃថ្មគោល មានក្បាច់ចិញ្ចៀន និងកំពករាងដូចផ្កាឈូក[9]។



ថ្មគោលស្ថិតក្នុងភូមិពានមាស

នៅមានថ្មគោល[10] ស្ថិតក្នុងភូមិត្រុំ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលមានរូបរាង ទំហំមិនខុសគ្នានឹងថ្មគោលរកឃើញនៅភូមិទួលគ្រួស ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។



ថ្មគោលរកឃើញនៅភូមិត្រុំ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

[9] ផុន កសិកា «ប្រាសាទរកឃើញថ្មីៗ និងការធ្វើផែនទីស្ថានីយបុរាណ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ» រាជបណ្ឌិត្យសភាកម្ពុជា, ២០១២ ទំព័រ៤៥។

[10] ហ្វេសប៊ុកផេកវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បង្ហោះនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ (https://www.facebook.com/share/p/15rJAaPvhx/)

# សន្និដ្ឋាន

ប្រាសាទអូរស្វាយគឺជាប្រាសាទដែលសាងសង់ពីថ្មភក់ ថ្មបាយក្រៀម និងមានប្ងង់ព្រមទាំងរចនាសម្ព័ន្ធផ្សេងទៀត ដូចជាគូទឹក និងបារាយណ៍ ដែលជាលក្ខណៈសំណង់ប្រាសាទកសាងក្នុងសម័យអង្គរ។ ជាពិសេសក្បាច់រចនានៅលើផ្តែរដែលមានក្នុងបរិវេណប្រាសាទបង្ហាញពីការរចនាក្នុងរចនាបថឃ្លាំងនាសតវត្សទី១១ ក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១។

បើយើងពិនិត្យលើសិលាចារឹកប្រាសាទអូរស្វាយ សិលាចារឹកនេះប្រហែលចារចាប់ពីពាក់កណ្តាលសតវត្សរ៍ទី១០ ឡើងទៅ បើយោងតាមទម្រង់នៃតួអក្សរ[11]។

ប្រសិនបើប្រាសាទស្ថិតនៅក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១ ករណីនេះក៏អាចកើតឡើងដែរ ដោយសារផ្តែរប្រាសាទស្ថិតរចនាបថឃ្លាំងក្នុងសតវត្សរ៍ទី១១។ ម៉្យាងវិញទៀត សិលាចារឹកអូរស្វាយគឺជាសិលាចារឹកចារអំពីការកំណត់ព្រំដីរបស់ទេវឋាន ឬ ទីតាំងកសាងប្រាសាទនៅតំបន់មួយឈ្មោះថា«ព្រៃឃ្មុំ»។ថ្មគោលដែលរកឃើញនៅភូមិទួលគ្រួស ឃុំអូរស្វាយ គឺជាភស្តុតាងបង្ហាញថា ការកំណត់ព្រំដីដែនសីមាត្រូវដាំបង្គោលសាងពីថ្មភក់ជាភស្តុតាង។



ប្រាសាទអូរស្វាយ ថតនៅភាគឦសាន

[11] វីដេអូឯកសារស្តីពី «សិលាចារឹកបង្ហាញព្រំដី នៅប្រាសាទអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ» បង្ហោះតាមហ្វេសប៊ុកផេកវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥។ (https://www.facebook.com/share/v/19BEgkQous/)

## ឯកសារពិគ្រោះ

-ផុន កសិកា «ប្រាសាទរកឃើញថ្មីៗ និងការធ្វើផែនទីស្ថានីយបុរាណ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ» រាជបណ្ឌិត្យសភាកម្ពុជា, ២០១២។

- មាឃ បូរ៉ា «វីដេអូឯកសារស្តីពី សិលាចារឹកបង្ហាញព្រំដី នៅប្រាសាទអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ» បង្ហោះតាមហ្វេសប៊ុកផេកវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ( https://www.facebook.com/share/v/19BEgkQous/ ) នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥។

-របាយការណ៍របស់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យចុះនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤។

-ហ្វេសប៊ុកផេកវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បង្ហោះនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ (https://www.facebook.com/share/p/15rJAaPvhx/)

-សម្ភាសលោក អ៊ិន អ៊ាន នៅបរិវេណប្រាសាទអូរស្វាយ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥។

- Boisselier, Jean., Asie du Sud-Est: I. Le Cambodge, Paris, 1966, p. 153.

- Chhum, M. (2020). Nine Deities Panel in Ancient Cambodia [ផ្ទាំងចម្លាក់ទេពប្រាំបួនអង្គក្នុងអារ្យធម៌ខ្មែរបុរាណ]. Pratu: Journal of Buddhist and Hindu Art, Architecture and Archaeology of Ancient to Premodern Southeast Asia, 1(2), 1-17. https://doi.org/10.25501/SOAS.00032560